ធនាគារអភិវឌ្ឍន៍ជនបទ
RURAL DEVELOPMENT BANK

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
Nation-Religion-King

លេខ / N° : ................................... ធ.អ.ជ / RDB

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន

ធនាគារអភិវឌ្ឍន៍ជនបទមានកិត្តិយសសូមជូនដំណឹងដល់សាធារណៈជន និងក្រុមហ៊ុនដែលពាក់ព័ន្ធទាំងអស់ជ្រាបថា÷ ធនាគារអភិវឌ្ឍន៍ជនបទ(ធ.អ.ជ.) ធ្លាប់បានធ្វើការផ្សព្វផ្សាយតាមរយៈគេហទំព័ររបស់ ធ.អ.ជ. សារព័ត៌មាន រស្មីកម្ពុជា និងកាសែត ខេមបូឌាដេលី រួចមកហើយ ស្តីអំពីសំណើចូលរួមដេញថ្លៃសម្រាប់គម្រោងក្នុងការអភិវឌ្ឍ និងធ្វើប្រតិបត្តិការលើឃ្លាំងស្តុកស្រូវចំនួន **២០០ ០០០តោន** និងឡសំងួតស្រូវដែលអាចសំងួតបាន **៣០០០ តោន**ក្នុងមួយថ្ងៃ ដែលមានទីតាំងនៅតំបន់បាត់ដំបង។ គិតចាប់ពីថ្ងៃផ្សព្វផ្សាយរហូតដល់ថ្ងៃផុតកំណត់បិទបញ្ចប់ការទទួលពាក្យស្នើសុំចូលរួមដេញថ្លៃ និងដាក់សំណើគម្រោង នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ ធនាគារអភិវឌ្ឍន៍ជនបទ បានទទួលសំណើចូលរួមដេញថ្លៃ និងដាក់សំណើគម្រោងពីក្រុមហ៊ុនចំនួន ៤ រួមមាន÷

១.ធនាគារស្រូវ (កម្ពុជា) ភីអិលស៊ី
២.ក្រុមហ៊ុនយែតថល ហូដ អ៊ិនវេសមេន អ៊ីមផង អ៊ិចផត ខូអិលធីឌី
៣.រោងម៉ាស៊ីនកិនស្រូវអ៊ឹងវណ្ណម៉ៅ
៤.ក្រុមហ៊ុន ANDURIZ (Cambodge) Sarl ។

បន្ទាប់ពីបានពិនិត្យវាយតម្លៃដោយឯករាជ្យពីក្រុមហ៊ុន Mekong Strategic Partner លើពាក្យស្នើសុំចូលរួមដេញថ្លៃ និងសំណើគម្រោង ព្រមទាំងឯកសារភ្ជាប់ រួចមក ក្រុមហ៊ុនចំនួន ៣ ត្រូវបានជាប់ក្នុងបញ្ជីសម្រាំង គឺ÷

១.ធនាគារស្រូវ (កម្ពុជា) ភីអិលស៊ី
២.ក្រុមហ៊ុនយែតថល ហូដ អ៊ិនវេសមេន អ៊ីមផង អ៊ិចផត ខូអិលធីឌី
៣.រោងម៉ាស៊ីនកិនស្រូវអ៊ឹងវណ្ណម៉ៅ។

នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ ក្រុមប្រឹក្សាភិបាល នៃធនាគារអភិវឌ្ឍន៍ជនបទបានប្រជុំពិនិត្យលើក្រុមហ៊ុនទាំង ៣ ដែលជាប់ក្នុងបញ្ជីសម្រាំង ដោយផ្អែកលើរបាយការណ៍វាយតម្លៃរបស់ក្រុមហ៊ុន Mekong Strategic Partner និងបន្ទាប់ពីបានពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក ក្រុមប្រឹក្សាភិបាល នៃធនាគារអភិវឌ្ឍន៍-ជនបទ បានសម្រេចជ្រើសរើសក្រុមហ៊ុន ធនាគារស្រូវ (កម្ពុជា) ភីអិលស៊ី ជាអ្នកទទួលបានសិទ្ធិក្នុងការអភិវឌ្ឍ និងធ្វើប្រតិបត្តិការលើឃ្លាំងស្តុកស្រូវចំនួន **២០០ ០០០តោន** និងឡសំងួតស្រូវដែលអាចសំងួតបាន **៣០០០ តោន** ក្នុងមួយថ្ងៃ ដែលមានទីតាំងនៅតំបន់បាត់ដំបង។

អាស្រ័យហេតុនេះសូមសាធារណៈជន និងក្រុមហ៊ុនដែលមានបទពិសោធន៍ពាក់ព័ន្ធទាំងអស់ជ្រាបជាព័ត៌មាន។

**ធនាគារអភិវឌ្ឍន៍ជនបទ**